# ការសំភាស៍របស់បងស្រី សែមស៊ីណា

កៈ អ្នកដែលសំភាស៍គេ អ៊ុំ ធីដា ខៈ អ្នកដែលអោយគេធ្វើការសំភាស៍ សែម ស៊ីណា

កៈ
ជាដំបូងខ្ញុំសុំថ្លែងអំណរគុណដល់បងស្រីដែលអោយខ្ញុំធ្វើការសំភាស៍ហើយកាលសំភាស៍មួយនិងគឺធ្វើដោយសារតែសកលវិទ្យាល័យByuដោយសារតែសកលវិទ្យាល័យនិងចង់ថែរក្សាជីវប្រវត្តរបស់ជីដូចជីតារបស់បង
និងបងទុកអោយកូនចៅជំនាន់ក្រោយមើលបានស្គាល់និងបានដឹងហើយបន្ទាប់ការសំភាស៍មួយនិងរួចហើយខ្ញុះសូមដាក់កាលសំភាស៍មួយនិងនៅក្នុងប្រពន្ធវើកផ្សាយរបស់សកលវិទ្យាល័យByuនិងតើបងអាចយល់ព្រមដែលទេបង?

ខៈ ចាខ្ញុំយល់ព្រម។

កៈ ខ្ញុំមានឈ្មោះថាអ៊ុំធីដាខ្ញុំបានធ្វើការសំភាស៍បងស្រីនៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ហើយខ្ញុំធ្វើការសំភាស៍មួយនេះនៅក្នុងថ្ងៃទី24ខែ03ឆ្នាំ2018ហើយតើបងស្រីមានឈ្មោះអ្វីដែលបង?

ខៈ សែម ស៊ីណា។

កៈ ចាហើយតើមានឈ្មោះហៅក្រៅទេបង?

ខៈ ខ្ញុំអត់មានផងនិង។

កៈ ហើយចុះដូចជាអាហាសនាមអីកាលពីតូចអីមានដែលទេបង?

ខៈ ចាអត់មានដែលនិង។

កៈ ចាអរគុណច្រើនបងតើក្នុងឆ្នាំនេះតើបងមានអាយុប៉ុន្មានដែលបង?

ខៈ ខ្ញុំមានអាយុ39ឆ្នាំហើយ.

កៈ ហើយតើបងដឹងថាបងកើតនៅក្នុងឆ្នាំណាដែលទេបង?

ខៈ កើតនៅឆ្នាំ1979។

កៈ
ចង់មាននៃថាបងបែបពីជំនាន់ពលពតហើយហើយក្នុងឆ្នាំច័ន្ទគិតតើបងកើតក្នុងឆ្នាំអ្វីដែលបង?គឺដូចជាឆ្នាំជូតឆ្លូវខាលថោះអីអញ្ចឹងបង?

ខៈ អូបងកើតនៅក្នុងឆ្នាំមមែ។

កៈ បងកើតនៅក្នុងឆ្នាំមមែគឺជាស្វតពពៃត្រូវទេបង។

ខៈ និងពពៃនិងគឺឆ្នាំមមែនិងហើយ។

កៈ ចាអញ្ចឹងតើបងកើតនៅក្នុងស្រុកមួយណាហើយភូមិឃុំខេត្តអ្វិដែលបង?

ខៈ ស្រុកកំនើតបងនៅតាកែវ។

កៈ នៅតាកែវភូមិឃុំអ្វីដែលទៅបង?

ខៈ
មិនដឹងថាភូមិឃុំអ្វីទេអត់ស្វស្គាល់ដែលព្រោះអីអត់បាននៅយូវផងបានផ្លាស់មកនៅកំពង់ចាមវិញនិង។

កៈ
អូស្រុកកំនើតនៅខេត្តតាកែវហើយបានផ្លាស់មកនៅកំពង់ចាមវិញន៍បងហើយស្រុកនិងគឺខាងប្តីរបស់បងមែនបង?

ខៈ ស្រុកម៉ែតែទៅនៅនិង។

កៈ អ៎។

ខៈ ទៅនៅនិងទាំងអស់គ្នា។

កៈ ចាបងហើយតើបងស្រីជាកូនទីប៉ុន្មានដែលទៅបង?

ខៈ ខ្ញុំកូនទីពីរ។

កៈ ហើយចុះតើបងមានសមាជិតគ្រួសារប៉ុន្មាននាក់ដែលបង?

ខៈ ដូចជាបងប្អូនបង្កើតនិងមានចំនួនប្រាំមួយនាក់។

ក៖ តើស្រីប៉ុន្មានហើយប្រុសប៉ុន្មានដែលទៅបង?

ខ៖ បងប្អូនមានស្រីបីប្រុសបី។

ក៖ អូអញ្ចឹងស្មើរគ្នានិងអញ្ចឹង។

ខ៖ ចានិងហើយ។

ក៖
ចាដូចខ្ញុំដែលប្រាំមួយនាក់ដែលនិងតែគ្រាន់ថាខ្ញុំវិញស្រីបួនហើយប្រុសពីរ។ចាហើយបងជាកូនទីប៉ុន្មានដែលទៅបង?

ខ៖ កូនទីពីរ។

ក៖
បងជាកូនទីពីរហើយតើបងអាចនិយាយរឿងកាលពីបងនៅពីក្មេងជាមួយនិងបងប្អូនរបស់បងដូចជាធ្លាប់ដើរលេងអីជាមួយនិងពួកគាត់អីអញ្ចឹងបងដូចជាពេលដែលបងនៅពីតូចៗជាមួយនិងគាត់ហើយអ្វីទៀតដែលបងនៅចងចាំអីអញ្ចឹងបង?

ខ៖ ដូចជាមិនសូវចាំអីនោះទេរឿងប្រវិត្តអីនិង។

ក៖
ដូចជាបងធ្លាប់ញុំាបាយអីជាមួយនិងពួកគាត់អីធ្លាប់លេងជាមួយនិងពួកគាត់ហើយធ្លាប់ដើរទៅរៀនអីជាមួយនិងគ្នាអីអញ្ចឹងឬក៏ធ្លាប់ធ្វើស្រែចំការអីនិងជាមួយនិងគ្នាអីអញ្ចឹងបង។

ខ៖
ធ្លាប់ធ្វើស្រែចំការអីនិងជាមួយនិងពួកគាត់តែគ្រាន់ថាពេលដែលធំដំបូងគឺតែពីនាក់បងប្អូននិងក្រៅពីនិងគឺនៅតូចៗនិងដូចជាមិនសូវចាំនោះទេ។

ក៖ ចាអញ្ចឹងតើពេងបងនៅពីក្មេងតើបងចូលចិត្តលេងអ្វិជាមួយនិងពួកគាត់ដែលបង?

ខ៖ ចូលចិត្តលេងលោត។

ក៖ លេងលោតអ្វីដែលបង?

ខ៖ លេងលោតស៊ូ។

ក៖ ហើយមានអ្វីទៀតទៅបង?

ខ៖ លេងឆុង។

ក៖ លេងឆុងគេលេងយ៉ាងមិចទៅបង?

ខ៖ កាលលេងនៅនោះគេហៅថាលេងឆុងតែបើលេងនេះខ្ញុំមិនដឹងថាគេហៅអីទេ។

ក៖ ហើយគេលែងមិចដែលបង?

ខ៖ លេងឆុងលេងដូចជាយើងនិងគូសធម្មតាអីនិង។

ក៖ បងលេងជាមួយនិងបងប្អូរបស់បងមែនទេ។

ខ៖ និងហើយ។

ក៖ តើពេលនេះតើពួកគាត់រស់នៅកន្លែងណាហើយពួកគាត់ប្រកបមុខរបរអ្វីដែលទៅបង?

ខ៖ ពួកគាត់រស់នៅស្រុកកំនើតទាំងអស់និង។

ក៖ ហើយពួកគាត់ធ្វើអ្វិដែលបង?

ខ៖ ពួកគាត់ធ្វើស្រែធ្វើចំការអីនិង។

ក៖ ចឹងបងប្អូនរបស់បងប្រាំនាក់ពួកគាត់នៅខេត្តហើយធ្វើស្រែចំការ។

ខ៖ ចានិងហើយ។

ក៖
ហើយចំនែកបងគឺមកនៅទីក្រុងភ្នំពេញហើយតើបងរស់នៅភ្នំពេញតើបងប្រកបមុខរបរអ្វីដែលទៅបង៕

ខ៖ មានទៅធ្វើអីទេនៅតែផ្ទះមើលតែកូនអីនិង។

ក៖ ហើយឥលូវនិងតើបងមានកូនចំនួនប៉ុន្មានហើយបង?

ខ៖ មានកូនតែមួយនិង។

ក៖ ពុំតែមានមួយនិងទេហើយតើគាត់បានប៉ុន្មានខួបហើយបង?

ខ៖ ពុំបានតែពីរខែនិង។

កៈ ហើយតើគាត់និងមានឈ្មោះអីដែលបង?

ខៈ ឈ្មោះថាវត្តទីយ៍។

កៈ ឈ្មោះឡើងពិរោះហើយត្រគោលរបស់គាត់ដាក់តាមប៉ាមែនទេ។

ខៈ ចាដាក់តាមប៉ារបស់គាត់។

កៈ ហើយតើឪពុកម្ដាយរបស់បងមានឈ្មោះអ្វីដែលបង?

ខៈ ម៉ែឈ្មោះថាសិន យឺន។

កៈ ហើយចុះឪពុកវិញអ្នកមីង?

ខៈ ឈ្មោះថាសែន ហ៊ត។

កៈ ហើយពួកគាត់ទាំងពីរមានអាយុប៉ុន្មានហើយបង?

ខៈ ម៉ែដូចជា60ហើយឪវីញគឺ60ជាងហើយឪ។

កៈ ហើយតើពួកគាត់ទាំងពីរកើតនៅក្នុងឆ្នាំណាមានចាំដែលទេ។

ខៈ អត់ចាំទេ។

កៈ
ចុះចំពោះឆ្នាំច័ន្ទគិតវិញតើពួកគាត់និងកើតនៅក្នុងឆ្នាំមួយណាដែលបងដូចជាឆ្នាំជូតឆ្នាំឆ្លូវ ខាលថោះអីអញ្ចឹងតើពួកគាត់មានដែលនិយាយអីប្រាប់ដល់បងដែលទេបង?

ខៈ ម៉ែដូចមិនដឹងថាឆ្នាំអីនោះទេម៉ែនិងហើយម៉ែកើតឆ្នាំកុរឪឆ្នាំមមែឆ្នាំមមែ។

កៈ ដូចជាឆ្នាំមមែដូចបងដែលមែនទេបង?

ខៈ និងហើយគាត់កើតជាន់ឆ្នាំគ្នាអីអញ្ចឹង។

កៈ
ចុះតើបងមានដឹងថាពួកគាត់និងកើតនៅស្រុកណាដែលទេឬក៏ជាអ្នកស្រុកណាអីដែលទេប ង?

ខៈ ពួកគាត់អ្នកខេត្តតាកែវ។

ក៖ អញ្ចឹងមានន័យថាពួកគាត់ជាអ្នកខេត្តតាកែវទាំងអស់គ្នាមែនបង។

ខ៖ និងពួកគាត់ទាំងពីនិងជាអ្នកខេត្តជាមួយនិងគ្នា។

ក៖ ចុះហេតុអ្វីបានជាបងផ្លាស់ទីលំនៅទៅខេត្តកំពង់ចាមវិញចឹងបង?

ខ៖ កាលនិងគាត់ទៅតាមទៅនៅជាមួយនិងគឺគាត់និង។

ក៖ ចុះមិនមែនជាស្រុកកំនើតរបស់គាត់ទេ។

ខ៖ និងហើយមិនមែនជាស្រុកកំនើតរបស់គាត់។

ក៖ ចុះចឹងតើគាត់មករកស៊ីអីអញ្ចឹងមែនបង?

ខ៖ និងគាត់ទៅរកស៊ីហើយក៏នៅនិងតែម្ដងទៅ។

ក៖ គាត់រកស៊ីនៅនិងតែម្ដងអ៎ហើយនៅខេត្តកំពង់ចាមអស់រយះពេលប៉ុន្មានឆ្នាំដែលបង?

ខ៖ មើលនៅជូរហើយដូចចាសាមសិបឆ្នាំអីជាងហើយ។

ក៖ សាមសិបឆ្នាំជាងចឹងរហូតមកមានគ្រួសារបងបែកមកពីភ្នំពេញវិញមកអញ្ចឹងមែនបង?

ខ៖ និងហើយ។

ក៖
ហើយចុះខេត្តតាកែវវិញដែលជាស្រុកកំនើតរបស់បងដែលបងរស់នៅវិញតើបងរស់នៅទីនោះអស់រយះពេលប៉ុន្មានឆ្នាំដែលបង?

ខ៖
ដូចជាអត់ចាំទេកាលនិងពេលនិងមិនដឹងថាប៉ុណ្ណាផងនិងម៉ែនាំមកនៅតាំងពីរតូចអីដឹងអីផងនិងពេលនិង។

ក៖ ហើយតើឪពុករបស់បងគាត់ធ្វើអ្វីសម្រាប់ចិញ្ចឹមជីវិតដែលបង?

ខ៖
គាត់មានទៅធ្វើអីគាត់ធ្វើតែស្រែចំការអីនិងហើយនៅខាងនិងគេធ្វើតែចំការនិងដាំបន្លែដាំអីនិង។

កៈ
ធ្វើចំការធ្វើស្រែចាហើយតើឪពុករបស់បងជាមនុស្សបែបណាដែលបង?គាត់ជាមនុស្សស្លូត
ឬក៏កាចអីអញ្ចឹងបង?

ខៈ គាត់ជាមនុស្សស្លូត។

កៈ ស្លូតហើយចុះម្ដាយរបស់បងវិញគាត់ធ្វើអ្វីសម្រាប់ចិញ្ចឹមជីវិតដែលបង?

ខៈ គាត់លក់បន្លែនៅផ្សារ។

កៈ នៅផ្សារតើផ្សារដែលគាត់លក់និងគឺនៅខេត្តណាដែលទៅបង?

ខៈ នៅផ្សារកំពង់ចាមយើងនិងគឺនៅស្រុកចំការលើខេត្តកំពង់ចាម។

កៈ ហើយចុះម្ដាយរបស់បងគាត់ជាមនុស្សបែបណាដែលទៅបង?

ខៈ ម្ដាយខ្ញុំស្លូតគាត់ស្រលាញ់កូនអីអញ្ចឹងហើយគាត់មិនដែលថាវៃកូនទេ។

កៈ ចាហើយចុះហើយនិងមាក់មួយណាគាត់កាចជាបងឬក៏គាត់ស្លូតទាំងដែលទៅបង?

ខៈ ឪគាត់រៀងកាចជាបន្តិច។

កៈ ហើយបងមានចងចាំអ្វីខ្លះដែលទាក់ទងនិងឪពុកម្ដាយរបស់បងដែលទេបង?

ខៈ គ្រាន់ដឹងថាពួកគាត់ស្រលាញ់គ្នាគិតពីកូនស្រលាញ់កូននិងប្រពន្ធ។

កៈ
ចុះតើបងមាននៅចងចាំរឿងផ្សេងទៀតដែលទេដែលបងគិតថាជារឿងដែលល្អសម្រាប់បង
។

ខៈ មានអីមានតែគាត់ស្រលាញ់កូនប្រដៅអោយកូននិងល្អ។

កៈ ចាអរគុណបងហើយតើបងមានចង់ចាំឈ្មោះជីដូននិងជីតារបស់មកដែលទេបង?

ខៈ តាឈ្មោះថា តាសែម ដល់ពេលយាយវីញគាត់មានឈ្មោះថាយាយសំ
តាសិនដល់ពេលយាយមួទៀតអត់ចាំផងនិង។

កៈ ពួកគាត់មួយណាខែម្ដាយមួយណាខែឪពុកដែលបង?

ខ៖
ខាងម៉ែឈ្មោះថាតាសិនហើយខាងឪឈ្មោះថាតាសែមហើយយាយវិញយាយសំខាងឪហើយយាយសំខាងម្ដាយមានតែប៉ុនហ្នឹង។

ក៖
ចាអរគុណបងហើយតើបងមានដឹងថាពួកគាត់ជាអ្នកស្រុកណាដែលទេឬក៏គាត់ទីកន្លែងកំនើតរបស់គាត់គឺនៅស្រុកណាខេត្តណាអីដែលបង?

ខ៖ ព្រោះអីឪគាត់នៅខាងនិងអីដែលនិង។

ក៖ ចុះថ្ងៃខែឆ្នាំកំនើតរបស់គាត់តើបងមានចាំទេបង?

ខ៖ អត់ចាំទេ។

ក៖
តើម៉ាកប៉ារបស់បងមានដែលនិយាយអ្វីដែលទាក់ទងជាមួយនិងជីដូនជីតប្រាប់ដល់បងដែលទេបង?

ខ៖ គាត់បាននិយាយតើតែគាត់និយាយតាំងពីតូចៗមកម្ល៉េសមានចាំអីបានណា។

ក៖
ចាអត់អីទេអរគុណច្រើនបង។ហើយតើក្រុមគ្រួសាររបស់បងរស់នៅទីក្រុងភ្នំពេញនេះអស់រយះពេលប៉ុន្មានឆ្នាំហើយបង?

ខ៖ ខ្ញុំមែន។

ក៖ ចាចាបង។

ខ៖
ខ្ញុំរស់នៅទីនេះប្រហែលជាដប់ឆ្នាំហើយខ្ញុំបានមកធ្វើការងាររោងចក្រអីនិងនៅកន្លែងនិង។

ក៖
ចឹងពេលដែលបងមានគ្រួសាររួចហើយបងមកធ្វើការនិងរកស៊ីនៅទីក្រុងភ្នំពេញមែនទេបង?

ខ៖ មកនៅមុនបានមានគ្រួសារនិងតាមក្រោយ។

កៈ អ៎ហើយតើបងមានសាច់ញ្ញាតិអីដែលរស់នៅក្រៅប្រទេសអីដែលទេបង?

ខៈ ខ្ញុំអត់មានទេ។

កៈ ហើយតើស្វាមីរបស់បងមានឈ្មោះអ្វីដែលបង។

ខៈ ឈ្មោះថា រ៉ុន វុធដ្ឋា។

កៈ ចាហើយដូចជាបងរៀនអាពាហ៍ពីពាហ៍នៅក្នុងខែឆ្នាំណាអីដែលបង?

ខៈ ឆ្នាំណាទេនាគ។

កៈ អាចគ្រាន់តែចាំតែឆ្នាំនិងក៏បានដែល។

ខៈ ដូចជា2000ប៉ុន្មានទេនាគភ្លេចបាត់ទៅហើយនាគនិងប្រហែលជា2003អីនិង។

កៈ 2003ហើយថ្ងៃខែអីវីញតើបងចាំទេបង?

ខៈ ថ្ងៃខែដូចជាអត់ចាំអីទេដល់មើលក្នុងរូបថតបានដឹង?

កៈ
ហើយតើអាពាហ៍ពិពាហ៍របស់បងនិងឪពុកម្ដាយរបស់ជាអ្នកដែលរាប់ចំអោយឬក៏យ៉ាងមិចដែលបង?

ខៈ និងមកពីកូនវាស្រលាញ់គ្នាផងគាត់មិនបង្ខំយើងអីផង៉េ

កៈ ហើយតើបងរៀបអាពាហ៍ពិពាហ៍នៅខេត្តដែលណ៎បង?

ខៈ និងការនៅខេត្តនិង។

កៈ
ហើយបានបងមកធ្វើការងារនៅទីក្រុងភ្នំពេញន៏បងណ៎។ចុះបងអាចប្រាប់ខ្ញុំពេលដំបូងដែលបងបានជួបជាមួយនិងបងប្រុសបានទេបង?

ខៈ មកធ្វើការងារជិតគ្នានិង។

កៈ ហើយបងចេះសរសេរនិងអានភាសាខ្មែរបានល្អប៉ុនណាដែលទៅបង?

ខៈ ចេះល្មមព្រោះអីរៀនាបានតិចតួចដែលនិង។

កៈ បងអាចមើលបាននិងអានបានដែលទេបង?

ខៈ និងអានបានមើលបានខ្លះ។

កៈ ចុះបងចេះភាសាក្រៅដែលទេបងដូចជាភាសាអង់គ្លេងនិងបារាំងនិងចិនអីទេបង

ខៈ អត់ចេះទេខ្ញុំ។

កៈ ហើយតើបានរៀនបានកំរិតថ្នាក់ទីប៉ុន្មានដែលបង?

ខៈ ការនិងរៀនបានថ្នាក់ទីប្រាំមកម្លេះ។

កៈ ហើយតើពេលដែលបងនៅរៀនតើបងរៀននៅសាលាណាដែលបង?

ខៈ រៀននៅស្រុកចំការលើស្រុកស្វាយទៀប។

កៈ សាលានិងមានឈ្មោះអ្វីដែលបង?

ខៈ ឈ្មោះថាបឋមសិក្សាស្វាយទៀប។

កៈ មិនមែនរៀននៅក្នុងវត្តអីទេន៏បង។

ខៈ អត់មានរៀនក្នុងវត្តណាអត់ទេ។

កៈ
ចាបងរៀនបានកំរិតថ្នាក់ទីប្រាំមកម្លេះ។ហើយដូចជាបងធ្លាប់មានមិត្តជិតស្និតអីដែលទេពេលដែលបងនៅរៀននិងបង។

ខៈ មាន។

កៈ តើបងអាចជួយរៀបរាប់ឈ្មោមិត្តរបស់បងបានទេបង?

ខៈ បានមួយឈ្មោះថាសុខលាភ សុផល។

កៈ ហើយពួកគាត់និងស្រីឬក៏ប្រុសដែលទៅបង?

ខៈ ស្រី។

កៈ ស្រីទាំងពីមែនទេបង?

ខ៖ ចា។

ក៖ តើមានមានធ្លាប់មានអនុស្សាវរីអីជាមួយពួកគាត់គិតថាជាពេលវេលាមួយដែលល្អអីអញ្ចឹងបង?

ខ៖ មានអីមានតែនាំគ្នាលេងអីតិចតួចហើយពេលដែលយើងរវល់ធ្វើអីអញ្ចឹងវិញគេនាំគ្នាមកលេងជាមួយនិងយើងដល់ផ្ទះហើយនាំគ្នាទៅដើរលេងជាមួយគ្នាដែល។គឺទៅលេងផ្ទះមិត្តភក្តិអីនិងហើយពេលដែលយើងនៅនិងវាក៏មិនសូវមានអីដែលយើងរៀងអត់ដែលនិងយើងមិនសូវធូធានអីដូចជាពួកគេទេយើងតែងតែរវល់អីអញ្ចឹងជាមួយនិងពួកគេអីអញ្ចឹងពេលដែល។

ក៖ ចុះបងពេលដែលបងទៅរៀនបងមនាដែលយកបាយអីទៅញុំានៅសាលាដែលទេបង?

ខ៖ អត់មានព្រោះអីសាលានិងគឺនៅជិតផ្ទះអីដែលនិង។

ក៖ ហើយតើបងធ្វើដើរទៅសាលានិងរយះប៉ុន្មានដែលបង?

ខ៖ ប្រហែលជាងដប់នាទីអីនិង។

ក៖ អូអញ្ចឹងដូចជាជិតដែលនិងហើយមិតរបស់ក៏ផ្ទះពួកគាត់នៅជិតបងដែល។

ខ៖ ចានិងហើយ។

ក៖ ហើយបងលេងតែជាមួយនិងមិតរបស់ហើយអត់មានអ្នកទៀតទេអ៎បង?

ខ៖ មានតើលេងជាមួយនិងមិត្តនិងអ្នកជិតខាងអីនិង។

ក៖ តើបងធ្លាប់ធ្វើការងារនៅវាលស្រែដែលទេបង?

ខ៖ ទៅចំការធ្លាប់ធ្វើចំការ។

ក៖ ហើយតើបងធ្លាប់ដំាអ្វីខ្លះដែលបង?

ខ៖ ដំាសណ្តែកសៀង និងគ្រាប់ល្ហុរអីនិងដាំសណ្តែកដីនិងដំាពោតអីនិង។

ក៖ ហើយរយះពេលប៉ុន្មានដែលបានផងដែលបង?

ខ៖ រយៈពលដែលបានផងនិងគឺអឺបីខែអីនិង។

ក៖ ហើយកាលធ្វើស្រែនិងចំការនិងតើខុសគ្នាបែកណាដែលទៅបង?

ខ៖ ធ្វើចំការគឺវាអត់ដូចជាធ្វើស្រែអីនោះទេគឺវាអត់ស្ទូវ ចុះទឹកដូចជាធ្វើស្រែអីនោះទេ។តែខ្ញុំអត់ដែលធ្វើស្រែអីទេតែធ្លាប់ធ្វើតែចំការអីនិង។

ក៖ ហើយតើក្នុងជីវិតរបស់បងតើបងធ្លាប់ឆ្លងកាត់ការងារអ្វីខ្លះដែលបង?

ខ៖
អូយរឿងជីវិតរបស់បងធ្លាប់ឆ្លងកាត់ច្រើនណាស់មកហើយគ្រាន់តែឈប់រៀនភ្លាមមកធ្វើការងារជួយគ្រួសារភ្លាមចេះដើរលក់នំលក់អីនិងហើយពេលដែលនេះនិងដាំផ្លែត្របែកនិងយើងមកលក់មកចិញ្ចឹមប្អូន។

ក៖
ហើយពេលដែលមកលក់នំនិងតើបងធ្វើខ្លួនបងឬក៏បងយកមកពីគេបងហើយបងលក់នំអ្វីខ្លះដែលបង?

ខ៖ ធ្វើខ្លួនឯងហើយយកទៅលក់នៅផ្សារ។

ក៖ ហើយតើជីវិតរបស់បងបានផ្លាស់ប្ដូរអ្វីខ្លះដែលទៅបង?

ខ៖
មើលទៅដូចជាផ្លាស់ប្ដូច្រើនណាស់ព្រោះតាំងពីក្មេងមកយើងអត់នៅផ្សេងអីទេគឺយើងចិញ្ចឹមបងប្អូនយើងហាត់អត់ដូចជាក្មេងពីឥឡូវនិងទេព្រោះអីយើងធំឡើងតែពីរនាក់បងប្អូននិងហើយដល់ពេលដែលយើងមានកូនទៅបានដឹងថាម៉ែយើងនិងគាត់ស្រលាញ់យើងយ៉ាងមិច។

ក៖
អញ្ចឹងដូចជាពេលដែលបងអត់ទាន់មានក្រុមគ្រួសារបងធ្វើការងារគ្រប់យ៉ាងដល់ពេលដែលបងមានគ្រួសារលក្ខណ៍ថាបងនៅតែផ្ទះមើលតែកូន។

ខ៖
និងហើយមកពីអត់មានអ្នកដែលជួយមើលបើមានអ្នកដែលជួយមើលវិញអោយគេមើលហើយទៅធ្វើការនិងគេដែលហើយ។

កៈ តើម្ហូបខ្មែរតើបងចូលចិត្តញុំាម្ហូបអ្វីជាគេដែលទៅបង?

ខៈ សម្លម្ជូរ។

កៈ សម្លម្ជូរអ្វីដែលបង?

ខៈ សម្លម្ជូរត្រកួន។

កៈ សាច់ត្រី។

ខៈ និងហើយសាច់ត្រី។

កៈ
ហើយចុះល្បែងប្រជាប្រិយខ្មែរវិញតើបងចូលចិត្តលេងល្បែងប្រជាប្រិយណាដែលបងដូចជាបោះអង្គញ់ បោះឈូក អីអញ្ចឹងបង?

ខៈ លេងបោះឈូក ។

កៈ ហើយលេងនៅណាដែលទៅបង?

ខៈ យើងលេងតែនៅស្រុកទេដល់ពេលមកនេះអត់សូវដែលបានលេងអីនោះទេ។

កៈ អញ្ចឹងពេលដែលចូលឆ្នាំបងទៅខេត្ត។

ខៈ
និងពេលដែលចូលឆ្នាំខ្ញុំទៅស្រុកវីញហើយអោយតែចិត្តដល់ពេលចូលឆ្នាំអីនិងនាំគ្នានិងលេងអីហើយ។

កៈ និងកាលដែលបងនៅពីក្មេងមែនបង?

ខៈ និងហើយ។

កៈ ដល់ពេលដែលបងធំហើយមានគ្រួសារអញ្ចឹងតើបងមានដែលលែងទៀតដែលទេបង?

ខៈ ដូចជាអត់ដែលលែងអីទេ។

កៈ តែបងអាចលេងបាន។

ខ៖
អាចលេងបានតែគ្មានពេលលេងនិងណា។ឥឡូវនិងសូមបីតែទៅស្រុកអីក៏អត់ដែលឃើញគេលេងដែលនិងគេច្រើនតែដើរលេងអីនិងគ្មានសូវលេងអត់ទេមានសុទ្ធតែក្មេងៗ។

ក៖ ហើយតើបទចំរៀងអ្វីដែលបងចូលចិត្តស្តាប់ជាងគេ?

ខ៖ និយាយរួចគឺប្រសិនបទនិងគឺពីរោះគឺខ្ញុំចូលចិត្តស្តាប់ជាងគេ។

ក៖ តើបងចូលចិត្តស្តាប់បទពីដើមឬក៏សម័យដែលបង?

ខ៖ បទសម័យគឺស្តាប់បានខ្លះដែលនិង។

ក៖ ហើយតើបងចូលស្តាប់បទណាជាងគេដែលបង?

ខ៖ បទពិដើមនិងមែន។

ក៖ ចាចា។

ខ៖ ព្រោះអីអ្នកចំរៀងពិដើមគឺគេជាងពិរោះផងនិង។

ក៖ ចុះដូចជាចំណងជាងបទចំរៀងតើបងមាននៅចាំដែលទេបង?

ខ៖ អត់ចាំទេចំណងតែគ្រាន់ថាចូលចិត្តស្តាប់។

ក៖
ហើយចុះតើដូចជាបងចូលចិត្តស្តាប់បទចំរៀងណាគេច្រៀងជាងគេដែលបងដែលបងគិតថាពេលដែលបងស្លាប់និងទៅបងអាចសប្បាយចិត្តអីអញ្ចឹង?

ខ៖ ដូចជាអត់សូវចាំទេ។

ក៖ ចឹងក្នុងគ្រួសាររបស់បងតើមានអ្នកណាដែលចេះលេងឧបករណ៍ភេងដែលទេបងុំ

ខ៖ អត់មានផង។

ក៖ ចុះខាងប្តីរបស់បងវិញបង?

ខ៖ ក៏អត់មានដែល។គឺអត់ទាំងអស់និង។

ក៖ អត់ទាំងអស់ន៏បង?

ខ៖ ចានិងហើយ។

ក៖ ហើយចុះបងតើផ្ទះរបស់បងមានលក្ខណ៍បែកណាដែលបង?

ខ៖ ផ្ទះធម្មតាអីនិង។

ក៖ ដូចជាមានលក្ខណៈបែបណាហើយតើវាសង់និងត្រូវប្រើឧបករណ៍អ្វីខ្លះដែលបង?

ខ៖ ធ្វើពីឈើ។

ក៖ ហើយតើមានអ្វីទៀត។

ខ៖ ឈើលើហើយថ្មអីក្រោមដែល។

ក៖ ហើយផ្ទះរបស់បងតើជួលគេសាងសង់ឬក៏ធ្វើដោយខ្លួនរបស់បងដែលបង?

ខ៖
សាងសង់ដោយខ្លួនឯងនិងយូរណាស់មកហើយតាំងពីនៅក្មេងៗមកតែបើផ្ទះខ្លួនឯងអីគឺអ
ត់ទាន់មានទេ។

ក៖
តើបងមានជំនាញអ្វីខ្លះដែលបន្តវពីក្រុងគ្រួសាររបស់ដែលទេបង?ដូចជាចេះធ្វើនំអីពីពូគា
ត់អីដឹងដែលទេបង?

ខ៖
មានអីពីមុននិងលក់ដែលនិងដល់ពេលដែលមកធ្វើការនិងទៅហើយខាតលក់ទៀតទៅ។

ក៖ លក់នំអីនិងបង។

ខ៖ លក់នំពុំអីនិងហើយឈប់លក់វាទៅមកលក់បន្លែវិញឥលូវនិង។

ក៖ ឥលូវនិងបងមកលក់បន្លែវិញនេបង។

ខ៖ ពេលទៅអញ្ចឹងទៅទៅជួយលក់បន្លែម៉ែអីអញ្ចឹងទៅ។

ក៖ តើបងអាចប្រាប់ខ្ញុំបានទេអំពីពេលវេលាដែលលំបាកនៅក្នុងជីវិតរបស់មកដែលទេបង?

ខ៖
ពេលដែលពិបាកជាងគេនិងគឺពេលដែលដាំបន្លែហើយយកលក់ព្រោះវាហាត់ហើយលំបាកអត់មានអ្នកណាគេជួយពួកយើងអីអញ្ចឹងផង។

ក៖ ដូចបងឆ្លងកាត់នៅកាលំបាកនិងដោយរបៀបណាដែលបង?

ខ៖ ថាមិចមិញ?

ក៖ ដូចជាបងឆ្លងកាត់នៅការលំបាកយ៉ាងមិចខ្លះដែលបង?

ខ៖
មានអីមកពីយើងនិងគិតថាយើងខំប្រឹងដើម្បីគ្រួសារអីអញ្ចឹងនិងមានអីគ្មានអ្នកណាមកជួយពួកយើងអីអញ្ចឹង។

ក៖ ចុះតើបងមានបទពិសោធ៏អ្វីខ្លះដែលល្អៗនៅក្នុងជីវិតរបស់បងដែលទេបង?

ខ៖
ពេលធ្វើចំការនិងមកឃើញពិបាកពេកក៏ម៉ែគាត់អោយមកធ្វើការរោងចក្រនិងទៅហើយពេលដែលធ្វើការងាររោងចក្រអីអញ្ចឹងទៅបានបានលុយខ្លះទៅនិងផ្ញើរទៅកាន់គាត់អីអញ្ចឹងនិងណា។

ក៖ ហើយពេលដែលមានគ្រួសារយ៉ាងមិចដែលទៅបង?

ខ៖ មានគ្រួសាររបស់យើងគាត់ទៅធ្វើការងារអីធម្មតាអីនិង។

ក៖ ពេលបងមកទីក្រុងភ្នំពេញបងជួយផ្ទះគេនៅមែនទេបង?

ខ៖ ផ្ទះបងនៅកន្លែងណាដែលទៅបង?

ក៖
ពេលដែលបងនៅពីក្មេងតើបងមានដែលគិតថាពេលដែលបងធំឡើងបងចង់មានជំនាញឬក៏ចង់ធ្វើជាគ្រូពេទ្យ គ្រូបង្រៀនអីដែលទេបង?

ខ៖
ខំរៀនដែលខំទៅប្រលងអីដែលតែអត់មានលុយអីរៀនតទៅទៀតអញ្ចឹងដូចថានៅផ្ទះនិងពិបាកពេកអីមានអ្នកណាអាចជួយរកលុយអីបានចឹង។

កៈ
ប្រសិនបើបងមានពេលលទ្ធភាពរៀនតទៅមុងទៀតតើបងមានក្ដីម៉ៃថាបងចង់ធ្វើជាអ្វីដែលពេលដែលបងធំឡើងបង?

ខៈ
ចង់រៀនភាសាអីនិងអោយបានច្រើនអីអញ្ចឹងទៅពេលដែលយើងចេះចង់ដើរបកប្រែអីអោយគេអីអញ្ចឹងតែវាមិនបាន។

កៈ បងមានអ្វីផ្ដាំទៅកាន់កូនចៅជំនាន់ក្រោយរបស់បងដែលទេបង?

ខៈ
អោយពួកគាត់និងខំប្រឹងរៀនអីអញ្ចឹងទៅរៀននិងអោយបានច្រើនអីទៅដូចបងចឹងធ្វើការដោយកំលាំងហើយវាមិនមែនជាការដែលស្រួលនោះទេខំប្រឹងរៀនហើយធ្វើការងារអីអញ្ចឹងទៅ។

កៈ ចុះបងមានអ្វីបន្ថែមទៀតដែលទេបង?

ខៈ អត់ទេមានតែប៉ុន្មាននិង។

កៈ
ចាអរគុណដល់បងហើយពួកយើងសុំថតរូបមួយដើម្បីក្នុងប្រព័ន្ធផ្សាយនិងការសំភាស៍មួយនិងផងដែលតើបងយល់ព្រមដែលទេបង?

ខៈ ចាព្រម។

កៈ អរគុណច្រើនបងជំរាបលាបង។

ខៈ ចាអរគុណអូន។

កៈ ជំរាបលាបង។